ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**

លេខ : ✓ មស.

## សាររំលែកមរណទុក្ខ

### ផ្ញើជូន

### លោក សូ វ៉ាង និងលោកស្រី ស៊ិន ស្រីឡា ព្រមទាំងក្រុមគ្រួសារ

ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការ នៃក្រសួងមុខងារសាធារណៈទាំងអស់ មានក្ដីសោកស្ដាយយ៉ាងក្រៃលែង ដោយបានទទួលដំណឹងថា **ឧបាសិកា លឹម យន់** ដែលត្រូវជាម្ដាយរបស់ **លោក សូវ៉ាង** និងត្រូវជាជីដូនរបស់ **លោកស្រី ស៊ិន ស្រីឡា** បានទទួលមរណភាព នាថ្ងៃសុក្រ ១២រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០២២ វេលាម៉ោង ១៩:៤៥នាទីយប់ ក្នុងជន្មាយុ ៨២ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយក្ដីរំជួលចិត្ត និងសមានទុក្ខដ៏ក្រៀមក្រំនេះ ខ្ញុំ និងថ្នាក់ដឹកនាំ ព្រមទាំងមន្ត្រីរាជការក្រសួងមុខងារសាធារណៈទាំងអស់ សូមចូលរួមសម្ដែងនូវក្ដីសោកស្ដាយ ស្រណោះ អាឡោះអាល័យបំផុតជាមួយ **លោក សូ វ៉ាង** ប្រធាននាយកដ្ឋានគ្រប់គ្រងឯកសារ និងស្ថិតិមន្ត្រីរាជការ និង**លោកស្រី ស៊ិន ស្រីឡា** ប្រធានការិយាល័យផ្ទៀងផ្ទាត់តារាងទូទាត់បៀវត្ស និងអាណត្តិបើកប្រាក់ ព្រមទាំងក្រុមគ្រួសារ ចំពោះការបាត់បង់ **ឧបាសិកា លឹម យន់** ដែលត្រូវជាម្ដាយ និងជីដូនជាទីគោរពស្រលាញ់ដ៏ឧត្ដុង្គឧត្ដមប្រកបដោយព្រហ្មវិហារធម៌។

យើងខ្ញុំទាំងអស់គ្នាសូមឧទ្ទិសបួងសួងជូនវិញ្ញាណក្ខន្ធ **ឧបាសិកា លឹម យន់** សូមអញ្ជើញទៅកាន់សុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **លោក សូ វ៉ាង និងលោកស្រី ស៊ិន ស្រីឡា ព្រមទាំងក្រុមគ្រួសារ** ទទួលនូវការរំលែកទុក្ខដ៏ក្រៀមក្រំបំផុត និងសេចក្ដីរាប់អានដ៏ជ្រាលជ្រៅពីយើងខ្ញុំ៕

ថ្ងៃ ច័ន្ទ ១៥រោច ខែពិសាខ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២២
**រដ្ឋមន្ត្រី**

ព្រុំ សុខា

ផ្លូវវេត្តអង្គតាម៉ិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh